# រឿងទី១១៖ សាវកប៉ុល

**ខគម្ពីរ៖ កិច្ចការ៩:១៥**

ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលមកគាត់វិញថា៖ «អញ្ជើញទៅចុះ! ដ្បិតខ្ញុំជ្រើសរើសបុរសនេះ ដើម្បីប្រើគាត់ អោយទៅប្រាប់ប្រជាជាតិ និងស្ដេចនានា ព្រមទាំងប្រាប់ជនជាតិអ៊ីស្រាអែល អោយស្គាល់ឈ្មោះខ្ញុំ

សូលជាមនុស្សដែលមានចំណេះដឹងខ្ពស់ខ្ពស់ ប៉ុន្តែ គាត់មិនស្គាល់ព្រះយេស៊ូទេ។ ហើយគាត់ក៏ជាអ្នកដែលស្អប់ និងតាមចាប់អ្នកណាដែលជឿព្រះយេស៊ូយកទៅដាក់គុកដែរ។
សូលបានទៅគេមហាបូជាចារ្យ រួចនិយាយថា៖ «សូមលោកជួយសរសេរសំបុត្រមួយដាក់ថា ឱ្យតែជួបពួកអ្នកជឿព្រះយេស៊ូនៅកន្លែងណា មិនថាជាអ្នកណាទេ ត្រូវចាប់បញ្ជូនមកក្រុងយេរូសាឡឹមទាំងអស់»។ សូលបានចេញដំណើរទៅក្រុងដាម៉ាស ដើម្បីតាមចាប់ពួកសិស្សដែលដើរតាមព្រះយេស៊ូ។
ពេលសូលទៅជិតដល់ក្រុងដាម៉ាស ស្រាប់តែមានពន្លឺមួយចាំងពីផ្ទៃមេឃមកជុំវិញគាត់។ ដោយសារចាំងភ្នែកខ្លាំងពេក ធ្វើឱ្យសូលមិនអាចបើកភ្នែកបាន។
សូលបានយកដៃមកបាំងដែរ ប៉ុន្តែដោយព្រោះពន្លឺនោះចាំងមកខ្លាំងពេក ទើបមើលអ្វីមិនឃើញទាំងអស់។
ពេលនោះ ស្រាប់តែមានសម្លេងពីលើមេឃមួយពោលមកគាត់ថា៖ «សូលអើយ សូល! ហេតុដូចម្ដេចបានជាអ្នកបៀតបៀនខ្ញុំ?»។
សូលបានសួរទៅវិញថា៖ «តើលោកជានរណា?» ព្រះយេស៊ូក៏ឆ្លើយថា៖ «ខ្ញុំជាយេស៊ូ ដែលអ្នកកំពុងតែស្អប់នោះហើយ»
សូលមិនជឿថាព្រះយេស៊ូជាស្ដេចដែលព្រះជាម្ចាស់បានសន្យាថានឹងប្រទានមកទេ ហើយក៏មិនជឿថាព្រះយេស៊ូដែលសុគតនៅលើឈើឆ្កាងនោះ មានព្រះជន្មរស់ឡើងវិញដែរ។ ដូច្នេះ ពេលលឺព្រះយេស៊ូមានបន្ទូលមកគាត់ហើយ គាត់មានការ ភ្ញាក់ផ្អើលជាខ្លាំង។
ភ្នែករបស់សូលត្រូវងងឹតមើលមិនឃើញអ្វីទាំងអស់ ហើយអ្នកដែលរួមដំណើរជាមួយគាត់បានដឹកដៃគាត់ចូលទៅក្រុងដាម៉ាស។
ក្នុងរយៈពេលបីថ្ងៃក្នុងក្រុងដាម៉ាស សូលមិនអាចមើលឃើញ ហើយក៏មិនពិសារបាយពិសាទឹកសោះឡើយ។
សូលបានទទួលស្គាល់កំហុសរបស់ខ្លួន ហើយបានអធិស្ឋានយ៉ាងអស់ពីចិត្តទៅព្រះយេស៊ូ។
ពេលនោះ នៅក្នុងក្រុងដាម៉ាសមានសិស្សរបស់ព្រះយេស៊ូម្នាក់ឈ្មោះអាណាណាស។
ព្រះយេស៊ូបានលេចមកក្នុងសុបិនរបស់គាត់ ទ្រង់មានបន្ទូលទៅគាត់ថា៖ «ចូរដាក់ដៃលើសូល ដើម្បីឱ្យគាត់មើលឃើញឡើងវិញ ដ្បិតខ្ញុំជ្រើសរើសបុរសនេះ ដើម្បីប្រើគាត់ឱ្យទៅប្រាប់ប្រជាជាតិ និងស្ដេចនានា ព្រមទាំងជនជាតិអ៊ីស្រាអែលដែលមិនស្គាល់ខ្ញុំ ឱ្យបានលឺពីព្រះនាមខ្ញុំ»។



លោកអាណាណាស ខ្លាចសូល ព្រោះលោកលឺថាគាត់ជាអ្នកបៀតបៀនធ្វើបាបពួកអ្នកដែលជឿព្រះយេស៊ូ។





ប៉ុន្តែ ដោយព្រោះព្រះយេស៊ូមានបន្ទូលមកគាត់ ដូច្នេះលោកក៏ចេញទៅរកសូលហើយដាក់ដៃលើគាត់ទូលអធិស្ឋាន។
ពេលអាណានាសអធិស្ឋានចប់ភ្លាម ដូចមានអ្វីមួយដូចជាស្រកាត្រី ជ្រុះចេញពីភ្នែកសូល លោកក៏មើលឃើញឡើងវិញ។
ហើយសូលក៏បានក្រោកឡើង ទទួលពិធីបុណ្យជ្រមុជទឹកពីអាណានាស។ នៅពេលនេះ សូលបានក្លាយជាសិស្សរបស់ព្រះយេស៊ូហើយ។
ក្រោយពីសូលពិសាអាហារហើយមានកម្លាំងឡើងវិញ គាត់បានចំណាយពេលនៅជាមួយពួកសាវក និងអ្នកដែលទទួលជឿព្រះយេស៊ូនៅក្នុងក្រុងដាម៉ាសជាយូរថ្ងៃ។
ហើយគាត់ក៏បានដើរប្រកាសផ្សព្វផ្សាយថា ព្រះយេស៊ូដែលគាត់បានជួបនោះជាបុត្ររបស់ព្រះជាម្ចាស់។
ក្រោយកន្លងទៅបានជាច្រើនថ្ងៃ ពួកជនជាតិយូដា បានចេញបញ្ជាឱ្យទាហានតាមឃ្លាំមើលតាមទ្វារក្រុងទាំងយប់ទាំងថ្ងៃដើម្បីចាប់សូលសម្លាប់។ ប៉ុន្តែ
សូលបានដឹងពីគម្រោងការរបស់ពួកគេ។
ដូច្នេះ ពួកសិស្សរបស់សូល បានដាក់សូលចូលទៅក្នុងកន្ត្រកដ៏ធំមួយ សម្រូតចុះមកក្រោយតាមជញ្ជាំងទ្វារក្រុងខាងក្រៅ ឱ្យគាត់រត់គេចខ្លួន។
សូលនេះហើយ ជាប៉ុលដែលជាអ្នកផ្សាយដំណឹងដ៏ល្បីល្បាញម្នាក់នោះ។
ទោះបីប៉ុលត្រូវជួបរឿងដ៏លំបាក និងវេទនាជាច្រើនយ៉ាងណាក៏ដោយ គាត់នៅតែបន្តដំណើរបេសកកម្មផ្សព្វផ្សាយពីព្រះបន្ទូល របស់ព្រះយេស៊ូនៅក្នុងប្រទេសជាច្រើន។
ហើយគាត់ក៏បានសរសេរនូវព្រះគម្ពីរសញ្ញាថ្មីបានចំនួនដប់បីក្បាលផងដែរ។



## សកម្មភាពទី១ សូមឆ្លើយនឹងសំណួរខាងក្រោម។

ក. តើសូលបានបៀតបៀនអ្នកណា?

--------------------------------------------------------------------------------

ខ. តើមានរឿងអ្វីបានកើតឡើងលើសូម ពេលដែលគាត់កំពុងធ្វើដំណើរទៅទីក្រុងដាម៉ាស?

--------------------------------------------------------------------------------

គ. តើព្រះយេស៊ូមានបន្ទូលទៅអ្នកណា តាមរយៈសុបិននិមិត្ត?

--------------------------------------------------------------------------------

ឃ. ក្រោយពីសូលបានទទួលជឿព្រះយេស៊ូហើយ គាត់បានប្តូរឈ្មោះ។ តើឈ្មោះថ្មីនោះ មានឈ្មោះអ្វី?

--------------------------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(កិច្ចការ៩:១៥)

**ដ្បិតខ្ញុំជ្រើសរើសបុរសនេះ ដើម្បីប្រើគាត់អោយទៅប្រាប់ប្រជាជាតិ និងស្តេចនានា ព្រមទាំងប្រាប់ជនជាតិអ៊ីស្រាអែល អោយស្គាល់ឈ្មោះខ្ញុំ**

**សកម្មភាពទី២** សូមជួយអាណាណាស ឱ្យបានទៅជួបនិងសូលដែលមើលមិនឃើញ។



KIDS GOD WORSHIP
www.kidsworship.kr

Selah
Ministerio de Publicación Cristiano

ឈ្មោះ: